# ជ្រុងមួយនៃទីផ្សារធានារ៉ាប់រងនៅកម្ពុជា

## ប្រវត្តិសង្ខេបនៃវិស័យធានារ៉ាប់រងនៅកម្ពុជា

ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាបានចាប់ផ្តើមនៅឆ្នាំ ១៩៥៦ ប៉ុន្តែត្រូវបានរំខានដោយសារតែរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៥ ។ ការអភិវឌ្ឍនៃវិស័យនេះ បានចាប់ផ្តើមឡើងវិញនៅដើមទសវត្សរ៍ ១៩៩០ ជាមួយនឹងបទប្បញ្ញត្តិតិចតួចដែលចាំបាច់ជាក់ស្តែងនៅពេលនោះ ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងដើម្បីធ្វើសំណងជូនជនរងគ្រោះចំពោះការខាតបង់ ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិគ្រោះថ្នាក់ចៃដន្យ និងព្រឹត្តិការណ៍អកុសលផ្សេងទៀតដែលអាចកើតមានឡើង។ ទោះជាយ៉ាងណាក៏ដោយ មុខងារពេញលេញនៃការធានារ៉ាប់រង ពោលគឺធានារ៉ាប់រងទូទៅ បានចាប់ផ្តើមជាមួយនឹងច្បាប់ធានារ៉ាប់រងនៅឆ្នាំ ២០០០ និងបទប្បញ្ញត្តិមួយចំនួនទៀតដែលបានដាក់ចេញក្នុងឆ្នាំបន្តបន្ទាប់ ។ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតទើបចាប់ផ្តើមមានវត្តមាននៅក្នុងទីផ្សារធានារ៉ាប់រងកម្ពុជាក្នុងឆ្នាំ ២០១២ ប៉ុណ្ណោះ។

**និយ័តករវិស័យធានារ៉ាប់រង**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមាននាយកដ្ឋានធានារ៉ាប់រងនិងសោធនជាដៃប្រតិបត្តិ គឺជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យ អាជីវកម្មធានារ៉ាប់រងនៅកម្ពុជា ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារសាធារណៈជនដែលជាអ្នកប្រើប្រាស់សេវាធានារ៉ាប់រង ដោយលើកទឹកចិត្តឲ្យមានការប្រកួតប្រជែងដោយស្មើភាពនៅក្នុងទីផ្សារធានារ៉ាប់រង និងធានាឲ្យមានសុច្ចរិតភាព និង ចិរភាពនៃឧស្សាហកម្មនេះ ។

**ប្រតិបត្តិករទីផ្សារធានារ៉ាប់រង និងសមាគមធានារ៉ាប់រងកម្ពុជា**

ទីផ្សារធានារ៉ាប់រងនៅកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ ប៉ុន្តែមានសន្ទុះកាន់តែខ្លាំងទៅៗ ដោយមានតួអង្គទីផ្សារកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ បច្ចុប្បន្ន មានក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវចំនួន ១៤ ក្នុងនោះមានក្រុមហ៊ុនធានារ៉ាប់រងទូទៅ ចំនួន ៧ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ចំនួន៣ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ចំនួន ៣ និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ចំនួន ១ ដែលកំពុងប្រតិបត្តិការនៅក្នុងទីផ្សារនៅកម្ពុជា ។

“**សមាគមធានារ៉ាប់រងទូទៅកម្ពុជា**” ត្រូវបានបង្កើតឡើង នៅឆ្នាំ ២០០៥ ក្នុងគោលបំណងដើម្បីចូលរួមចំណែកអភិវឌ្ឍនិងពង្រឹងវិស័យធានារ៉ាប់រងនេះបន្ថែមទៀត ។ នៅពេលនោះមានតែការធានារ៉ាប់រងទូទៅ ដែលមានវត្តមាននៅក្នុងទីផ្សារ ចំណែកឯធានារ៉ាប់រងអាយុជីវិតទើបមានវត្តមាននៅកម្ពុជានៅឆ្នាំ២០១២ ប៉ុណ្ណោះ។ “**សមាគមធានារ៉ាប់រងទូទៅកម្ពុជា**” បានផ្លាស់ប្តូរឈ្មោះទៅជា “**សមាគមធានារ៉ាប់រង កម្ពុជា (សធក)**” ក្នុងឆ្នាំ ២០១៣ ស្របពេលដែលមានវត្តមានចូលរួមរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ។ ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងជីវិត និង ក្រុមហ៊ុនធានារ៉ាប់រង

Insurance Association of Cambodia: #17, St.134, Sangkat Mittapheap, Khan 7 Makara, Phnom Penh, Cambodia.
Tel: +855 92 778 111, Fax: +855 23 986 516, Email: info@iac.org.kh, Website: www.iac.org.kh.

បន្ត ទាំងអស់ ដែលកំពុងមានប្រតិបត្តិការក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា គឺជាសមាជិករបស់ “**សមាគមធានារ៉ាប់រងកម្ពុជា**” ។

គោលបំណងចម្បងៗមួយចំនួន របស់ “**សមាគមធានារ៉ាប់រងកម្ពុជា**” គឺ បង្កើតឲ្យមានមតិរួមក្នុងចំណោមសមាជិកទាំងអស់ចំពោះការដោះស្រាយបញ្ហា និងការបារម្ភនានាដែលកើតមាននៅក្នុងឧស្សាហកម្មនេះ ការលើកកម្ពស់កេរ្តិ៍ឈ្មោះនិងចំណេះដឹងសាធារណៈនៃឧស្សាហកម្មធានារ៉ាប់រង ការលើកកម្ពស់ជំនាញនិងស្តង់ដារវិជ្ជាជីវៈនៅក្នុងឧស្សាហកម្ម ក៏ដូចជាការជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាន និងស្ថិតិនៃវិស័យធានារ៉ាប់រងទាំងមូល ។

## ការអភិវឌ្ឍនៃទីផ្សារធានារ៉ាប់រងនាពេលបច្ចុប្បន្ន

ចាប់តាំងពីមានច្បាប់ធានារ៉ាប់រងក្នុងឆ្នាំ២០០០ បទប្បញ្ញត្តិផ្សេងៗ ក៏ដូចជាគោលនយោបាយធានារ៉ាប់រងដែលត្រូវបានដាក់ចេញជាបន្តបន្ទាប់ ឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជា បានរីកចម្រើនគួរឲ្យកត់សម្គាល់ ។ ផ្តើមដំបូងមានតែធានារ៉ាប់រងទូទៅប៉ុណ្ណោះហើយរហូតដល់ឆ្នាំ២០១២ ទើបធានារ៉ាប់រងអាយុជីវិតនិងធានារ៉ាប់រងខ្នាតតូចមានវត្តមាននៅក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា ។ ការវិវត្តនេះបានធ្វើឲ្យវិស័យធានារ៉ាប់រង កាន់តែបង្កើនតួនាទី និងសារៈសំខាន់របស់ខ្លួននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុកាន់តែខ្លាំងពោល គឺមិនត្រឹមតែបង្កើតឲ្យមានផលិតផលធានារ៉ាប់រងសម្រាប់សហគ្រាស អាជីវកម្ម និងប្រជាពលរដ្ឋដែលមានចំណូលមធ្យមនិងខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវផលិតផលធានារ៉ាប់រង ដែលអាចបំពេញតម្រូវការរបស់ប្រជាពលរដ្ឋដែលមានចំណូលទាបផងដែរ ។

**បុព្វលាភដុល និងសំណងទូទាត់របស់ធានារ៉ាប់រងទូទៅ ២០០៩-២០១៤(ជា US$)**




ដោយសារតែក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងអាយុជីវិត ទើបចាប់កំណើតថ្មី ដូចនេះស្ថិតិទីផ្សារខ្លះសម្រាប់ក្រុមហ៊ុនទាំងពីរប្រភេទនេះ មិនត្រូវបានបង្ហាញនៅក្នុងអត្ថបទនេះទេ ខណៈពេលដែលក្រុម

ហ៊ុនធានារ៉ាប់រងទូទៅមានកំណើនដ៏រឹងមាំ ។ ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ បុព្វលាភដុលនៃធានារ៉ាប់រងទូទៅ បានកើនឡើងជាមធ្យមប្រមាណ ១៩.៧%ក្នុងមួយឆ្នាំ ពោលគឺកើនឡើងពី ៨.៨ លានដុល្លារក្នុងឆ្នាំ ២០០៥ ទៅ ៥៣ លានដុល្លារក្នុងឆ្នាំ ២០១៤ ។ ក្នុងឆ្នាំ ២០១៤ កំណើនបុព្វលាភដុលធានារ៉ាប់រងទូទៅ មានកម្រិតខ្ពស់ដល់ទៅ ២៦.៧% ។ ជាការឆ្លើយតបចំពោះហានិភ័យដែលបានកើតឡើងហើយដែលមានការធានារ៉ាប់រង ឧស្សាហកម្មធានារ៉ាប់រងបានធ្វើការទូទាត់សំណងយ៉ាងត្រឹមត្រូវជូនទៅអ្នកត្រូវបានធានារ៉ាប់រង ។ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ សំណងបានទូទាត់ជាមធ្យមមាន ១៤.៨ លានដុល្លារ ក្នុងមួយឆ្នាំ ។ ដូច្នេះ សំណងដែលបានទូទាត់ដោយក្រុមហ៊ុនធានារ៉ាប់រងកន្លង ពិតជាបានសម្រាលបន្ទុកហិរញ្ញវត្ថុចំពោះបុគ្គលត្រូវបានធានារ៉ាប់រង ដោយសារតែការខូចខាតបង្កឡើងដោយព្រឹត្តិការណ៍មិនបានដឹងជាមុន។

សម្រាប់ព័ត៌មានបន្ថែមសាធារណជនអាចធ្វើការទំនាក់ទំនងមកកាន់សមាគមធានារ៉ាប់រកម្ពុជាតាមរយៈទូរស័ព្ទលេខ ០៩២ ៧៧៨ ១១១ និងអាចតាមដានរកព័ត៌មានបន្ថែមក្នុងគេហទំព័ររបស់សមាគមwww.iac.org.khនិងបណ្តាញសង្គមហ្វេសប៊ុកwww.facebook.com/iaccambodia ។